# សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយឆ្នាំ២០១៩

## សំណួរដែលសួរជាញឹកញាប់

### តើសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយគឺជាអ្វី?

សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ(CPI) ធ្វើការផ្តល់ពិន្ទុ និងចំណាត់ថ្នាក់ចំពោះបណ្តាប្រទេស និងដែនដីនានា តាមរយៈការវាយតម្លៃពីទំហំនៃអំពើពុករលួយក្នុងវិស័យសាធារណៈរបស់ប្រទេសទាំងនោះ ដោយផ្អែកលើការយល់ឃើញរបស់អ្នកជំនាញ និងអ្នកប្រតិបត្តិធុរកិច្ច។ សន្ទស្សន៍CPI គឺជាការគណនាបញ្ចូលគ្នានៃការស្ទង់មតិ និងការវាយតម្លៃពីអំពើពុករលួយ ចំនួន ១៣ របស់ស្ថាប័នដែលមានកិត្តិនាមផ្សេងៗ។ សន្ទស្សន៍CPI គឺជាសូចនាករនៃអំពើពុករលួយដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅទូទាំងពិភពលោក។

### តើប្រភពទិន្នន័យអ្វីខ្លះ ដែលត្រូវបានប្រើប្រាស់សម្រាប់សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ?

សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយឆ្នាំ២០១៩ ត្រូវបានគណនាដោយប្រើប្រាស់ប្រភពទិន្នន័យចំនួន ១៣ របស់ស្ថាប័នឯករាជ្យចំនួន ១២ដែលមានជំនាញក្នុងការវិភាគអំពីអភិបាលកិច្ច និងបរិយាកាសអាជីវកម្ម។ ប្រភពព័ត៌មានដែលត្រូវបានប្រើប្រាស់សម្រាប់សន្ទស្សន៍CPIឆ្នាំ២០១៩ គឺផ្អែកទៅលើទិន្នន័យដែលត្រូវបានចេញផ្សាយក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ។ សន្ទស្សន៍CPI ប្រើប្រាស់តែប្រភពទិន្នន័យទាំងឡាយណាដែលផ្តល់ពិន្ទុចំពោះបណ្តាប្រទេស និងដែនដីទាំងអស់(ឬភាគច្រើន) និងវាយតម្លៃអំពីការយល់ឃើញរបស់អ្នកជំនាញពាក់ព័ន្ធនឹងអំពើពុករលួយនៅក្នុងវិស័យសាធារណៈក្នុងប្រទេសទាំងនោះ។ អង្គការតម្លាភាពអន្តរជាតិពិនិត្យយ៉ាងម៉ត់ចត់ទៅលើវិធីសាស្ត្រស្រាវជ្រាវរបស់ប្រភពទិន្នន័យនីមួយៗ ដើម្បីធានាថាទិន្នន័យទាំងនោះសមស្របទៅតាមស្តង់ដាគុណភាពរបស់អង្គការតម្លាភាពអន្តរជាតិ។ សម្រាប់ព័ត៌មានលម្អិតអំពីប្រភពទិន្នន័យ ប្រភេទអ្នកចូលរួមសម្ភាសន៍ ហើយនិងកម្រងសំណួរស្រាវជ្រាវ សូមចូលទៅអានឯកសារពិពណ៌នាអំពីប្រភពទិន្នន័យរបស់សន្ទស្សន៍CPIនេះ។

### ហេតុអ្វីបានជាយើងត្រូវការសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ ប្រសិនបើមានប្រភពទិន្នន័យចំនួន ១៣ ផ្សេងទៀត ធ្វើការវាយតម្លៃពីអំពើពុករលួយនៅក្នុងវិស័យសាធារណៈរួចហើយ?

គុណសម្បត្តិ ៤ចំនុច ដែលធ្វើឱ្យសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ គឺជាសូចនាករមួយដ៏មានតម្លៃផ្នែកអភិបាលកិច្ច រួមមាន៖

1. សន្ទស្សន៍ CPI មានវិសាលភាពគ្របដណ្តប់លើភូមិសាស្ត្រជាលក្ខណៈសកល
2. សន្ទស្សន៍ CPI មានភាពគួរឱ្យទុកចិត្តជាងប្រភពនីមួយៗដែលត្រូវបានយកមកប្រើប្រាស់ដោយឡែក ព្រោះវាទូទាត់បន្ថយភាពខុសឆ្គងបានមួយកម្រិតថែមទៀតពីលើទិន្នន័យទាំងនោះ ដោយសន្ទស្សន៍

CPI ធ្វើការគណនាពិន្ទុជាមធ្យមដោយប្រើប្រាស់ទិន្នន័យយ៉ាងហោចណាស់ ៣ផ្សេងគ្នា ឬច្រើនរហូតដល់ ១៣ទិន្នន័យ។

3. សន្ទស្សន៍CPI មានមាត្រដ្ឋានពិន្ទុពី 0 ទៅ១០០ ដែលអាចញែករកភាពខុសគ្នាបានកាន់តែប្រសើរពាក់ព័ន្ធនឹងការយល់ឃើញពីអំពើពុករលួយ បើធៀបនឹងទិន្នន័យទាំងនោះដែលមានមាត្រដ្ឋានពិន្ទុត្រឹម ១-៧ ឬ ១-១០ប៉ុណ្ណោះសម្រាប់ប្រទេសនីមួយៗ
4. ខណៈប្រភពទិន្នន័យទាំងនោះវាយតម្លៃពីលក្ខណៈផ្សេងៗគ្នានៃអំពើពុករលួយក្នុងវិស័យសាធារណៈ ដូចនេះសន្ទស្សន៍CPI គឺជាការច្របាច់បញ្ចូលគ្នានូវទិដ្ឋភាពផ្សេងគ្នានៃអំពើពុករលួយទាំងនោះឱ្យទៅជាសូចនាករតែមួយ។

## ហេតុអ្វីសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយត្រូវបានវាយតម្លៃដោយពឹងផ្អែកទៅលើការយល់ឃើញ?

ជាទូទៅ អំពើពុករលួយ គឺជាសកម្មភាពខុសច្បាប់ទាំងឡាយណាដែលមានភាពលាក់កំបាំងដោយចេតនា និងអាចត្រូវបានរកឃើញតាមរយៈរឿងអាស្រូវ ការស៊ើបអង្កេត ឬការផ្តន្ទាទោសប៉ុណ្ណោះ។ ខណៈអ្នកស្រាវជ្រាវមកពីមជ្ឈដ្ឋានបញ្ញវន្ត សង្គមស៊ីវិល និងរដ្ឋាភិបាលបានធ្វើការងារជាច្រើនទាក់ទងនឹងការវាយតម្លៃពីអំពើពុករលួយក្នុងវិស័យជាក់លាក់មួយចំនួន ប៉ុន្តែបច្ចុប្បន្ននេះពុំមានសូចនាករណាមួយដែលវាយតម្លៃពីអំពើពុករលួយនៅកម្រិតថ្នាក់ជាតិដោយផ្ទាល់ និងល្អិតល្អន់នោះឡើយ។ ដើម្បីធ្វើឱ្យសន្ទស្សន៍CPIលេចជារូបរាងឡើង ប្រភពទិន្នន័យ និងការស្ទង់មតិទាំងអស់ខាងលើបានប្រើប្រាស់នូវកម្រងសំណួរដែលបានឆ្លងកាត់ការរៀបចំយ៉ាងយកចិត្តទុកដាក់ដើម្បីប្រមូលព័ត៌មានពីអ្នកចូលរួមសម្ភាសន៍ម្នាក់ៗ។ (សម្រាប់ព័ត៌មានលម្អិតអំពីប្រភពទិន្នន័យ និងកម្រងសំណួរទាំងនោះ សូមអានទីនេះ។) សន្ទស្សន៍CPIបានប្រមូលនូវការយល់ឃើញរបស់ភាគីពាក់ព័ន្ធនានា ដែលជាទូទៅមានទំនាក់ទំនងយ៉ាងខ្លាំងទៅលើសូចនាករនៃអំពើពុករលួយ ដូចជាបទពិសោធន៍របស់ប្រជាពលរដ្ឋនៅក្នុងសំណូកជាដើម ត្រូវបានសិក្សានៅក្នុងការវាស់វែងពីអំពើពុករលួយជាសកល(GCB)។

## តើមានប្រទេស ឬដែនដីណាខ្លះ ដែលត្រូវបានយកមកសិក្សានៅក្នុងសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយឆ្នាំ២០១៩? ហេតុអ្វី?

ចំពោះប្រទេស ឬដែនដីមួយដែលត្រូវបានដាក់បញ្ចូលនៅក្នុងការធ្វើចំណាត់ថ្នាក់នេះ ប្រទេសនោះត្រូវតែមានប្រភពទិន្នន័យយ៉ាងហោចណាស់ចំនួន ៣របស់សន្ទស្សន៍CPI។ ប្រសិនបើមានប្រទេសណាមួយមិនត្រូវបានដាក់បញ្ចូលទៅក្នុងចំណាត់ថ្នាក់របស់សន្ទស្សន៍នេះ មានន័យថាចំនួនប្រភពទិន្នន័យសម្រាប់ប្រទេសនោះមិនគ្រប់គ្រាន់ ហើយក៏មិនមែនមានន័យថាប្រទេសនោះគ្មានអំពើពុករលួយដែរ។ ក្នុងឆ្នាំនេះ មានប្រទេស និងដែនដីសរុបចំនួន ១៨០ ត្រូវបានដាក់បញ្ចូលក្នុងការវាយតម្លៃ គឺដូចទៅនឹងឆ្នាំ២០១៧ និងឆ្នាំ២០១៨ដែរ។

## តើអ្វីជាភាពខុសគ្នារវាងចំណាត់ថ្នាក់ និងពិន្ទុរបស់ប្រទេស ឬដែនដីទាំងនោះ?

ពិន្ទុរបស់ប្រទេស/ដែនដីមួយចង្អុលបង្ហាញពីកម្រិតនៃការយល់ឃើញពីអំពើពុករលួយនៅក្នុងវិស័យសាធារណៈនៅលើមាត្រដ្ឋានពិន្ទុពី0-១០០ ដែល0 មានន័យថាពុករលួយខ្លាំង ហើយ១០០គឺស្អាតស្អំខ្លាំង។ ចំណាត់ថ្នាក់របស់ប្រទេសនីមួយៗបង្ហាញពីលេខរៀងរបស់ប្រទេសនោះធៀបនឹងប្រទេសផ្សេងទៀតដែលមាន

ក្នុងសន្ទស្សន៍នេះ។ ចំណាត់ថ្នាក់អាចមានការផ្លាស់ប្តូរ ប្រសិនបើចំនួនប្រទេសដែលត្រូវបានដាក់បញ្ចូលទៅក្នុងសន្ទស្សន៍នេះមានការផ្លាស់ប្តូរ។

**តើសន្ទស្សន៍ CPI គ្របដណ្តប់ទៅលើទិដ្ឋភាពអ្វីខ្លះនៃអំពើពុករលួយ?**

ប្រភពទិន្នន័យរបស់សន្ទស្សន៍CPI គ្របដណ្តប់លើទិដ្ឋភាពនៃអំពើពុករលួយដូចខាងក្រោម ដោយផ្អែកលើកម្រងសំណួរជាក់លាក់ដែលត្រូវបានប្រើដើម្បីប្រមូលទិន្នន័យ៖

- សំណូក
- ការបង្វែរមូលនិធិសាធារណៈ
- ការរីករាលដាលនៃមន្ត្រីដែលប្រើប្រាស់តួនាទីរដ្ឋដើម្បីផលប្រយោជន៍ឯកជន ដោយមិនប្រឈមនឹងទណ្ឌកម្មនាពេលខាងមុខ
- លទ្ធភាពរបស់រដ្ឋាភិបាលក្នុងការទប់ស្កាត់អំពើពុករលួយ និងពង្រឹងយន្តការសុចរិតភាពប្រកបដោយប្រសិទ្ធភាពនៅក្នុងវិស័យសាធារណៈ
- បែបបទរដ្ឋបាល និងការិយាធិបតេយ្យហួសហេតុ ដែលអាចបង្កើនឱកាសនៃការប្រព្រឹត្តអំពើពុករលួយ
- ការតែងតាំងតួនាទីដោយផ្អែកលើសមត្ថភាព និងផ្អែកលើបក្ខពួកនិយមនៅក្នុងវិស័យសាធារណៈ
- ការផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធភាពទៅលើមន្ត្រីពុករលួយ
- ការមានច្បាប់គ្រប់គ្រាន់ស្តីពីការបញ្ចេញព័ត៌មានហិរញ្ញវត្ថុ និងការបញ្ចៀសទំនាស់ផលប្រយោជន៍ក្នុងចំណោមមន្ត្រីសាធារណៈ
- ការគាំពារផ្នែកច្បាប់ទៅលើបុគ្គលរាយការណ៍ អ្នកកាសែត និងអ្នកស៊ើបអង្កេត នៅពេលពួកគេរាយការណ៍ករណីសំណូក និងអំពើពុករលួយ
- ឥទ្ធិពលរបស់ធុរជនទៅលើមន្ត្រីសាធារណៈ
- សិទ្ធិរបស់សង្គមស៊ីវិលក្នុងការទទួលបានព័ត៌មានអំពីកិច្ចការសាធារណៈ។

សម្រាប់កម្រងសំណួរទាំងស្រុងដែលត្រូវបានប្រើប្រាស់ដោយប្រភពទិន្នន័យរបស់សន្ទស្សន៍CPI សូមស្វែងរកឯកសារពិពណ៌នាអំពីប្រភពទិន្នន័យទាំងនោះ។

**តើទិដ្ឋភាពអ្វីខ្លះនៃអំពើពុករលួយ ដែលសន្ទស្សន៍ CPI មិនគ្របដណ្តប់?**

ប្រភពទិន្នន័យរបស់សន្ទស្សន៍CPI មិនគ្រប់ដណ្តប់លើទិដ្ឋភាពនៃអំពើពុករលួយ ដូចខាងក្រោមទេ៖

- ការយល់ឃើញ ឬបទពិសោធន៍របស់ប្រជាពលរដ្ឋទាក់ទងនឹងអំពើពុករលួយ
- ការគេចបន្ធំពន្ធ
- លំហូរហិរញ្ញវត្ថុទុច្ចរិត
- អ្នកដែលអាចជំរុញឱ្យមានអំពើពុករលួយ (មេធាវី គណនេយ្យករ ទីប្រឹក្សាហិរញ្ញវត្ថុជាដើម)
- ការលាងលុយកខ្វក់
- អំពើពុករលួយក្នុងវិស័យឯកជន
- សេដ្ឋកិច្ចនិងទីផ្សារក្រៅផ្លូវការ។

### តើប្រទេស/ដែនដីដែលទទួលបានពិន្ទុទាបជាងគេ គឺជាប្រទេសដែលមានអំពើពុករលួយធ្ងន់ធ្ងរបំផុតលើពិភពលោកមែនឬទេ?

មិនមែនទេ។ សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយគឺជាសូចនាករនៃការយល់ឃើញពីអំពើពុករលួយនៅក្នុងវិស័យសាធារណៈដូចជា អំពើពុករលួយក្នុងផ្នែករដ្ឋបាល និងនយោបាយជាដើម។ វាមិនមែនជាការវិនិច្ឆ័យទៅលើកម្រិតនៃអំពីពុករលួយរបស់ប្រទេស ឬសង្គមមួយទាំងស្រុង ឬទៅលើគោលនយោបាយ ឬសកម្មភាពរបស់ស្ថាប័នឯកជនរបស់ប្រទេសនោះឡើយ។ ប្រជាពលរដ្ឋរបស់ប្រទេស/ដែលទទួលបានចំណាត់ថ្នាក់ទាបនៅក្នុងសន្ទស្សន៍នេះ ជារឿយៗបង្ហាញនូវក្តីបារម្ភស្រដៀងៗគ្នា និងធ្វើការថ្កោលទោសទៅលើអំពើពុករលួយ ក៏ដូចគ្នាទៅនឹងប្រជាពលរដ្ឋដែលនៅក្នុងប្រទេសដែលទទួលបានពិន្ទុខ្ពស់ផងដែរ។

ជាងនេះទៅទៀត ប្រទេស/ដែនដីដែលទទួលបានពិន្ទុទាបជាងគេ គឺជាប្រទេសដែលត្រូវបានយល់ឃើញថា វិស័យសាធារណៈមានអំពើពុករលួយធ្ងន់ធ្ងរក្នុងចំណោមប្រទេសដទៃទៀតដែលស្ថិតនៅក្នុងសន្ទស្សន៍នេះ។ ហើយសន្ទស្សន៍នេះមិនបានផ្តល់ព័ត៌មានទាក់ទងនឹងប្រទេស/ដែនដីផ្សេងទៀតដែលមិនត្រូវបានដាក់បញ្ចូលទៅក្នុងការធ្វើចំណាត់ថ្នាក់ឡើយ។

### តើពិន្ទុក្នុងឆ្នាំ២០១៩របស់ប្រទេសមួយ អាចប្រៀបធៀបជាមួយនឹងឆ្នាំមុនៗបានដែរឬទេ?

បាន។ ជាផ្នែកមួយនៃការកែសម្រួលវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ដើម្បីគណនាសន្ទស្សន៍CPI នៅឆ្នាំ២០១២ យើងបានបង្កើតមាត្រដ្ឋានពិន្ទុថ្មីពី0-១០០។ ពិន្ទុរបស់ប្រទេសនីមួយៗដែលត្រូវបានផ្តល់ឱ្យដោយប្រភពទិន្នន័យទាំងនោះ ត្រូវបានគណនាមាត្រដ្ឋានឡើងវិញ ដោយប្រើប្រាស់មធ្យមភាគ និងគម្លាតស្តង់ដាលក្ខណៈសកល ចាប់តាំងឆ្នាំ២០១២។ តាមរយៈការប្រើប្រាស់មាត្រដ្ឋាននេះ យើងអាចប្រៀបធៀបពិន្ទុសន្ទស្សន៍ CPI ក្នុងឆ្នាំមួយទៅឆ្នាំមួយទៀតបាន រាប់ពីឆ្នាំ២០១២មក។ ដោយសារការកែសម្រួលវិធីសាស្ត្រនេះ ពិន្ទុនៃសន្ទស្សន៍CPI នៅមុនឆ្នាំ២០១២ មិនអាចប្រៀបធៀបគ្នាបានទេ។

សម្រាប់ព័ត៌មានបន្ថែមអំពីការកែសម្រួលវិធីសាស្ត្រក្នុងឆ្នាំ២០១២ សូមចូលទៅកាន់៖ Corruption Perceptions Index – An updated Methodology for 2012.

### តើខ្ញុំអាចស្វែងរកតារាងលទ្ធផលទាំងស្រុងទៅតាមឆ្នាំផ្សេងៗនៅឯណា?

អ្នកអាចស្វែងរកព័ត៌មាននេះនៅលើគេហទំព័ររបស់យើងនៅទីនេះ។

### ខ្ញុំចង់បង្កើតឡើងនូវលទ្ធផលសន្ទស្សន៍ CPI សម្រាប់ការបោះពុម្ពផ្សាយផ្ទាល់ខ្លួនរបស់ខ្ញុំ។ តើខ្ញុំត្រូវការស្នើសុំការអនុញ្ញាតដែរឬទេ?

ទេ។ លុះត្រាតែមានការណែនាំបែបនោះ។ មាតិការបស់អង្គការតម្លាភាពអន្តរជាតិ ត្រូវបានរ៉ាប់រងដោយអាជ្ញាប័ណ្ណCreative Commons Attribution-NoDerivs 4.0។ នេះមានន័យថាអ្នកមានសេរីភាពក្នុងការប្រើការងាររបស់យើងដោយមិនចាំបាច់ទាក់ទងមកយើងទេ ដរាបណាអ្នកអនុលោមទៅតាមលក្ខខណ្ឌនៅក្នុងអាជ្ញាប័ណ្ណនោះ។ ហើយអ្នកអនុលោមតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ដរាបណាអ្នកបង្ហាញប្រាប់ពីឯកសារយោង និងតំណភ្ជាប់ទៅកាន់ឯកសាររបស់យើង ដូចខាងក្រោម៖

**ចំណងជើងមាតិកា (ឆ្នាំ) ដោយអង្គការតម្លាភាពអន្តរជាតិ មានអាជ្ញាប័ណ្ណ CC-BY-ND 4.0**

សូមដាក់តំណភ្ជាប់ទៅកាន់មាតិការបស់អង្គការតម្លាភាពអន្តរជាតិ ក្រោម **ចំណងជើងមាតិកា (ឆ្នាំ)** ដែលបានបញ្ជាក់ខាងលើ។

លក្ខណៈ "NoDerivs" មានន័យថា វាមិនត្រូវបានអនុញ្ញាតឱ្យបញ្ចូល ឬផ្លាស់ប្តូរមាតិកានៅក្រោមអាជ្ញាប័ណ្ណដែលបានបញ្ជាក់នោះឡើយ។

## តើខ្ញុំអាចប្រៀបធៀបលទ្ធផលដែលមានមុនឆ្នាំ២០១២បានដែរឬទេ?

ទេ។ ដោយសារការកែសម្រួលវិធីសាស្ត្ររបស់យើងក្នុងឆ្នាំ២០១២ លទ្ធផលសន្ទស្សន៍មុនឆ្នាំនោះ មិនអាចយកមកធ្វើការប្រៀបធៀបបានទេ។ មានតែលទ្ធផលសន្ទស្សន៍ចាប់ពីឆ្នាំ ២០១២ប៉ុណ្ណោះ ដែលអាចយកមកគ្នាប្រៀបធៀបបាន។

## តើខ្ញុំអាចប្រៀបធៀបរវាងប្រទេសនានាបានដែរឬទេ បើប្រទេសទាំងនោះត្រូវបានវាយតំលៃដោយប្រភពទិន្នន័យផ្សេងៗគ្នា?

បាន។ តាមរយៈដំណើរការនៃគណនាពិន្ទុឡើងវិញតាមមាត្រដ្ឋានរបស់យើង ប្រភពទិន្នន័យទាំងនោះកាន់ខិតទៅជិតមធ្យមភាគសកល និងគម្លាតស្តង់ដា ដោយមានទិន្នន័យឆ្នាំ២០១២ជាមូលដ្ឋាន ដើម្បីអនុញ្ញាតឱ្យមានការប្រៀបធៀបទៅតាមពេលវេលា។ ចំពោះការបកស្រាយទាំងស្រុងនៃដំណើរការគណនាមាត្រដ្ឋានពិន្ទុឡើងវិញរបស់ពួកយើង សូមអាចកំណត់សម្គាល់ស្តីពី វិធីសាស្ត្របច្ចេកទេស។

## ប្រទេសរបស់ខ្ញុំបានផ្លាស់ប្តូរពិន្ទុសន្ទស្សន៍ CPI ចំនួន ១ ឬ២ពិន្ទុ។ តើនេះមានន័យថាអំពើពុករលួយបានកើនឡើង/ថយចុះដែរឬទេ?

សន្ទស្សន៍CPI គឺជាសូចនាករមានលក្ខណៈផ្សំបញ្ចូលគ្នា ដែលយ៉ាងហោចណាស់មានប្រភពទិន្នន័យចំនួន៣ ត្រូវបានប្រើសម្រាប់ប្រទេសមួយក្នុងការគណនាពិន្ទុសន្ទស្សន៍នេះ។ ចំពោះបណ្តាប្រទេសមួយចំនួនប្រភពទិន្នន័យទាំងនោះបានផ្តល់ពិន្ទុឱ្យស្រដៀងៗគ្នា ខណៈប្រទេសផ្សេងទៀត ទទួលបានពិន្ទុឆ្ងាយពីគ្នា។ យើងរាយការណ៍ពីភាពខុសគ្នានេះ ដោយប្រើប្រាស់កំហុសស្តង់ដា និងកំរិតខ្ពស់ និងទាបនៃចន្លោះជឿទុកចិត្ត។ ប្រទេសដែលទទួលបានពិន្ទុស្រដៀងៗគ្នាផ្តល់ឱ្យដោយប្រភពទិន្នន័យទាំងនោះ នឹងមានកំហុសស្តង់ដាតូច ខណៈប្រទេសដែលមានពិន្ទុខុសគ្នាច្រើន នឹងមានកំហុសស្តង់ដាធំ។ ការប្រែប្រួលពិន្ទុសន្ទស្សន៍ CPI ចំនួន ១ ឬ ២ពិន្ទុ មិនមានន័យថា ពិតជាមានការផ្លាស់ប្តូរតាមបែបស្ថិតិទេ។ ការប្រែប្រួលតាមបែបស្ថិតិ ត្រូវបានរាយការណ៍នៅក្នុងតារាងលទ្ធផល Excel របស់យើង។ សូមអានឯកសារ Excel ដែលមានចំណងជើងថា៖ "Statistically Signifcant Changes" ។

## តើសន្ទស្សន៍ CPI អាចប្រាប់ព័ត៌មានពេញលេញពីអំពើពុករលួយនៅក្នុងប្រទេសណាមួយបានដែរឬទេ?

ទេ។ សន្ទស្សន៍CPI ត្រូវបានកំណត់នៅក្នុងវិសាលភាពមួយ ដែលគ្រប់ដណ្តប់ទំហំនៃការយល់ឃើញពីអំពើពុករលួយនៅក្នុងវិស័យសាធារណៈ របស់អ្នកជំនាញ និងអ្នកប្រកបការងារក្នុងប្រទេសនោះ។ ដើម្បីបំពេញនូវទស្សនៈនេះហើយទាញយកទិដ្ឋភាពផ្សេងៗគ្នានៃអំពើពុករលួយ អង្គការតម្លាភាពអន្តរជាតិ បានផលិតការស្រាវជ្រាវពីអំពើពុករលួយទាំងបែបគុណភាព និងបរិមាណទាំងនៅក្នុងកម្រិតពិភពលោកដែលធ្វើឡើងដោយលេខាធិការដ្ឋានរបស់ខ្លួន និងនៅថ្នាក់ជាតិតាមរយៈសាខាអង្គការតម្លាភាពអន្តរជាតិដែលមានមូលដ្ឋាននៅក្នុងប្រទេសជាង១០០ នៅជុំវិញពិភពលោក។

បន្ថែមលើសន្ទស្សន៍ CPI នេះ អង្គការតម្លាភាពអន្តរជាតិ មានឯកសារស្រាវជ្រាវជាលក្ខណៈសកលតំបន់ និងការស្រាវជ្រាវតាមវិស័យដទៃទៀត។ ព័ត៌មានលម្អិត អាចរកបានតាមគេហទំព័ររបស់យើង។

## តើមានការត្រួតពិនិត្យឯករាជ្យ លើសុពលភាពនៃវិធីសាស្រ្តរបស់សន្ទស្សន៍ CPI ដែរឬទេ?

មជ្ឈមណ្ឌលស្រាវជ្រាវរួមនៃគណៈកម្មការអឺរ៉ុប បានធ្វើសវនកម្មឯករាជ្យលើសន្ទស្សន៍ CPI ឆ្នាំ២០១៧ និងវិធីសាស្រ្តរបស់សន្ទស្សន៍នេះ។ ការធ្វើសវនកម្មដូចគ្នានេះ ត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០១២ បន្ទាប់ពីមានការបញ្ចូលវិធីសាស្រ្តថ្មីមួយសម្រាប់គណនាសន្ទស្សន៍ CPI ។ សវនកម្មទាំងពីរបានរកឃើញថា សន្ទស្សន៍ CPI គឺមានប្រទាក់ក្រឡាគ្នាតាមលក្ខណៈទស្សនទាននិងផ្នែកស្ថិតិ ព្រមទាំងមានរចនាសម្ព័ន្ធដែលមានតុល្យភាព។ របាយការណ៍ និងអនុសាសន៍ទាំងស្រុងអាចរកបាននៅគេហទំព័ររបស់យើង។

## តើការផ្លាស់ប្តូរតាមបែបស្ថិតិត្រូវបានគណនាយ៉ាងដូចម្តេច?

ចាប់តាំងពីឆ្នាំ២០១៨ អង្គការតម្លាភាពអន្តរជាតិប្រើប្រាស់វិធីសាស្រ្តមួយដែលត្រូវបានកែសម្រួលដើម្បីគណនាកំហុសស្តង់ដា និងទំហំប្រសិទ្ធភាព ដោយផ្អែកលើដំបូន្មានរបស់មជ្ឈមណ្ឌលស្រាវជ្រាវរួមនៃគណៈកម្មការអឺរ៉ុប។ ការផ្លាស់ប្តូរតាមបែបស្ថិតិត្រូវបានគណនាដោយប្រើទំហំប្រសិទ្ធភាព គម្លាតស្តង់ដា និងចំនួនប្រភពទិន្នន័យដែលត្រូវបានប្រើសម្រាប់ប្រទេសនីមួយៗ។ ការប្រែប្រួលពិន្ទុសន្ទស្សន៍CPI ត្រូវបានចាត់ទុកថាមានសារៈសំខាន់តាមបែបស្ថិតិ ដោយប្រើចន្លោះជឿទុកចិត្តកម្រិត ៩០%។ ការពិពណ៌នាទាំងស្រុង រួមទាំងរូបមន្តនានា អាចរកបាននៅក្នុងកំណត់ចំណាំស្តីពី វិធីសាស្រ្តបច្ចេកទេស។